

# ដំណាំម្រះ

## ការរៀបចំដីដាំ

រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ សង់ទីម៉ែត យ៉ាងតិចនៅរដូវវស្សា)ពង្រាយជីលាមកគោស្ងួតរឺជីកំប៉ុស្ត៍ និងជីកែងៗពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អគ្របរងដោយគំរបដីផ្លាស់ស្ទិក រឺ ចំបើងអោយបានកំរាស់យ៉ាងតិច៥សង់ទីម៉ែត្រដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី។



*ការបង្ហូរទឹកចូលធ្វើឲ្យដីមានសំណើម*

## ការបណ្តុះគ្រាប់

ត្រាំគ្រាប់ក្នុងងទឹកក្តៅឧណ្ហៗ រយៈពេលពី ១៥ ទៅ ២០ នាទី (រដូវក្តៅអាចដាក់គ្រាប់បណ្តុះតែម្តងបាន) ពង្រាយគ្រាប់ដែលបានត្រាំហើយលើក្រណាត់សើមហើយជក់ទឹក មូរក្រណាត់នេះរួចយកទុកក្នុងកន្លែងងងឹតត្រូវរក្សាក្រណាត់ដែលបានមូរឲ្យមានសំណើម តែមិនត្រូវអោយសើមពេកទេបន្ទាប់ពីផ្អាប់២ថ្ងៃគ្រាប់នឹងបែកមាត់ នោះយើងអាចយកគ្រាប់នេះទៅដាក់បណ្តុះក្នុងកន្ទោង រឺថាសបណ្តុះបាន។

## ការបណ្តុះកូន

រៀបចំកន្ទោងបណ្តុះ (ស្លឹកត្នោត រឺស្លឹកចេក) រឺ ថាសបណ្តុះ យកដីមានជីជាតិ(ដីដំបូក)១ភាគ ជីកំប៉ុស្តិ៍រឺជីលាមកគោដែលរលួយ១ភាគ និងផេះអង្កាម១ ភាគ លាយជាមួយគ្នាហើយ យកទៅលីងអោយក្តៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង។ បណ្តុះតែ១គ្រាប់ក្នុងមួយកន្ទោង ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្រប្រអំពីស្លឹកដូងឬសំណាញ់កាត់ពន្លឺនៅរដូវក្តៅ។ រដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺ និងទឹកច្រើនទេ។ស្រោចទឹក១ថ្ងៃមួយដងនៅពេលព្រឹក (បើទុកដីបណ្តុះស្ងួត គ្រាប់មិនអាចដុះបានទេ បើកូនដុះហើយក៏នៅក្រិនដែរ)



## ការដាំកូនម្រះ

កូនអាយុបាន ៧ថ្ងៃ អាចយកទៅដាំបាន ត្រូវដាក់កូនម្រះអោយត្រូវចំពន្លឺថ្ងៃបានចំនួន២-៣ថ្ងៃមុនដាំដើម្បីអោយកូនរឹងមាំល្អហើយផ្សាំនិងអាកាសធាតុខាងក្រៅបានស្រោចទឹកកូនម្រះឲ្យសើមល្មមនៅពេលព្រឹក ហើយចាប់ផ្តើមដាំកូនម្រះនៅពេលរសៀលយកកូនចេញពីកន្ទោង រឺថាសបណ្តុះដោយប្រុងប្រយ័ត្នបំផុត មិនត្រូវអោយដាច់ឫសកូនម្រះឡើយត្រូវដឹងថាកូនម្រះត្រូវការស្រោចទឹកអោយបានគ្រប់គ្រាន់ ជាពិសេសរវាងពី ២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយត្រូវដោតទ្រើងភ្លាមបន្ទាប់ពីដាំពីព្រោះម្រះដុះលូតលាស់លឿនណាស់ បើទុកអោយវាធំទើបដោតទ្រើងធ្វើអោយដាច់ឫសដំណាំ



## ការថែទាំ

គួរកាត់ស្លឹកដែលនៅក្បែរដីចេញ និងកាត់ខ្នែងទាំងឡាយណាដែលនៅកំពស់ពីដីកន្លះម៉ែត្រចុះមកក្រោមត្រូវស្រោចទឹកឲ្យបានគ្រប់គ្រាន់នៅពេលព្រឹក ជៀសវាងស្រោចទឹកច្រើនពេកធ្វើឲ្យដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហាដល់ ដំណាំបាន។



